ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៨ លេខ ០២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងកិច្ចព្រមព្រៀងរវាងអង្គការហាមឃាត់អាវុធគីមី(OPCW)និងរដ្ឋភាគីស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ OPCW | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកទេស | ៣ |
| ៣- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៥ |
| ៤- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមករា ឆ្នាំ២០១៥ | ៦ |
| ៥- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |

## សេចក្តីព្រាងកិច្ចព្រមព្រៀងរវាង អង្គការហាមឃាត់អាវុធគីមី(OPCW)និងរដ្ឋភាគីស្តីពី

# បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ OPCW

កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ហុង ថា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងកិច្ចព្រមព្រៀងរវាងអង្គការហាមឃាត់អាវុធគីមី(OPCW)និងរដ្ឋភាគីស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ OPCW** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រី នៃក.ស.វ. សមាជិកនិងមន្ត្រី នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងអាជ្ញាធរជាតិអាវុធគីមី។



អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលអាណត្តិទី៥នៃរដ្ឋសភាដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញអនុសាសន៍ដ៏ថ្លៃថ្លាជាបន្តបន្ទាប់ពិសេសលើការពង្រឹងនីតិរដ្ឋ នយោបាយការពារជាតិ ការពារដាច់ខាតនូវឯកភាព អធិបតេយ្យភាព បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឲ្យបានគង់វង្ស សន្តិសុខសណ្តាប់ធ្នាប់សាធារណៈឲ្យបានរឹងមាំគ្រប់កាលៈទេសៈ និងចូលរួមក្នុងបេសកកម្មរក្សាសន្តិសុខជាសកលរបស់អង្គការសហប្រជាជាតិនាពេលបច្ចុប្បន្ន និងកំពុងបន្តទៅអនាគត ដើម្បីទប់ស្កាត់នូវការរីកសាយភាយអាវុធមហាប្រល័យ ដែលកំពុងកើតមានឡើងនៅមជ្ឈឹមបូព៌ា ឧបទ្វីបកូរ៉េ និងនៅក្នុងសកលលោក ជាពិសេសមជ្ឈឹមបូព៌ា ដែលកំពុងទទួលនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរបំផុតពីសំណាក់ក្រុមភេរវករអន្តរជាតិដោយបានយកសារធាតុគីមីគ្រប់ប្រភេទមកផ្សំធ្វើជាគ្រឿងផ្ទុះ សម្រាប់ប្រើប្រាស់ក្នុងការវាយប្រហារគ្រប់ប្រភេទយ៉ាងសាហាវឃោរឃៅព្រៃផ្សៃបំផុតនៅតាមទីប្រជុំជន អគាររដ្ឋាភិបាល វង្គសាល ក្លឹបរាត្រី។ល។ បានសម្លាប់មនុស្សរាប់ម៉ឺននាក់ និងរបួសរាប់សែន គួរឲ្យសង្វេកក្រៃលែង។ ក្រៅពីភារកិច្ចខាងលើពេលថ្មីៗកន្លងមកនេះ

ព្រះរាជាណាចក្រកម្ពុជាបានធ្វើជាប្រធានអាស៊ាន និងជាម្ចាស់ផ្ទះបានរៀបចំកិច្ចប្រជុំអាស៊ានប្រកបដោយជោគជ័យជាវិជ្ជមាន។

ដោយយល់ឃើញថា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ និងជាសកលទទួលបាននូវជោគជ័យមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តបំពេញតួនាទីដោយឈរលើបុគ្គលិកលក្ខណៈស្របច្បាប់នេះ អគ្គលេខាធិការដ្ឋាននៃអង្គការហាមឃាត់អាវុធគីមី (OPCW) បានតាក់តែងកិច្ចព្រមព្រៀងនេះឡើងក្នុងគោលបំណងសង្កត់ធ្ងន់ទៅលើអភ័យឯកសិទ្ធិនិងបុព្វសិទ្ធិរបស់មន្ត្រីនៃអង្គការហាមឃាត់អាវុធគីមី។ បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិនេះ គឺជាសិទ្ធិពិសេសដែលផ្តល់ឲ្យមន្ត្រីនៃអង្គការហាមឃាត់អាវុធគីមីនៅពេលបំពេញបេសកកម្មតាមបណ្តារដ្ឋឲ្យផុតពីអំណាចយុត្តាធិការរបស់រដ្ឋ ដែលបានចុះហត្ថលេខា និងបានផ្តល់សច្ចាប័ន។ កិច្ចព្រមព្រៀងនេះមានទម្រង់ដូចគ្នាទៅនឹងអនុសញ្ញាទីក្រុងវីយែនស្តីពីការទំនាក់ទំនងការទូតដែលអង្គសន្និសីទបានឯកភាព និងសម្រេចជាឯកច្ឆ័ន្ទនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១[១]។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចឲ្យសាមីស្ថាប័នកែសម្រួលការបកប្រែភាសាឡើងវិញ ហើយដាក់ប្រជុំម្តងទៀតនៅពេលក្រោយ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងនេះ។

[១] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងអង្គការហាមឃាត់អាវុធគីមី (OPCW) និងរដ្ឋភាគីស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ OPCW ។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំនិងការប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកទេស

កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព លោកជំទាវ **គាល់ ណៃអ៊ីម** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **លឹម សំអាត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកទេស** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រី នៃក.ស.វ. សមាជិកនិងមន្ត្រី នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។



ក្រសួងផែនការបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកទេស ដោយយោងតាមមាត្រាទី៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដោយមានជំនួយពីអ្នកច្បាប់ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃសាធារណរដ្ឋកូរ៉េ ដែលជាប្រទេសមានការអភិវឌ្ឍប្រកបដោយជោគជ័យយ៉ាងធំធេងនិងឆាប់រហ័សលើគ្រប់វិស័យបន្ទាប់ពីចប់សង្គ្រាមដ៏មហន្តរាយក្នុងទស្សវត្សរ៍ទី៥០ ផ្អែកលើវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍ។

សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានកែសម្រួលនិងកែលម្អជាបន្តបន្ទាប់ទៅតាមអនុសាសន៍ដែលបានមកពីការពិភាក្សានិងការប្រជុំដូចខាងក្រោម៖

-អង្គប្រជុំគណៈកម្មាធិការដឹកនាំបច្ចេកទេសគម្រោងផែនការមេថ្នាក់ជាតិផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឆ្នាំ២០១៤-២០២០ ដែលមាន ១៤ ក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលជាសមាជិក និងតំណាងក្រុមប្រឹក្សាអ្នកច្បាប់។



-សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិដែលមានតំណាងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ ព្រមទាំងមន្ត្រីជំនាញនៃសាធារណៈរដ្ឋកូរ៉េ។

-ការប្រជុំនៃសមាសភាពក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្ដីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងនេះទាំងស្រុង។



(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុនៃសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកទេស។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃអង្គារ ទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ នៅវេលាម៉ោង ១៦:០០នាទីល្ងាច នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និងសមាជិក ECOSOCC ឯកឧត្តម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្រសួងសាមី និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់និង ការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់។

ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចនិងឯកភាពធ្វើការកែសម្រួលលើមាត្រាដូចខាងក្រោម៖

**ជំពូកទី៤ លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណផ្លូវថ្នល់**

- មាត្រា៩ កថាខណ្ឌទី១ និងកថាខណ្ឌទី២ ត្រេទី៣ បន្ថែមឃ្លា "**ក្នុងករណីនីតិបុគ្គលជាក្រុមហ៊ុនបទពិសោធ នេះសំដៅដល់បទពិសោធរបស់ក្រុមហ៊ុន**" នៅខាងចុងឃ្លា។



**ជំពូកទី៦ បទប្បញ្ញត្តិដោយឡែក**

- មាត្រា១៦ បន្ថែមកថាខណ្ឌថ្មី "ក្រុមហ៊ុនជាតិ និងក្រុមហ៊ុនបរទេសដែលទទួលបានអាជ្ញាបណ្ណត្រូវធានាថាវិស្វករបរទេសដែលក្រុមហ៊ុនយកមកបម្រើការនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជិការនៅគណៈវិស្វករកម្ពុជា" ។

**ជំពូកទី៧ ទណ្ឌកម្ម**

- មាត្រា១៨ ពាក្យ "**និង**" ប្តូរទៅជាពាក្យ "**ឬ**" នីបន្ទាប់ពីពាក្យ "**ផ្លូវថ្នល់**" ។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានលើកការប្រជុំនៅវេលាម៉ោង១៨:៣០នាទី ហើយបង្កើតក្រុមការងារចង្អៀត ដោយមានការចូលរួមពីក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍជនបទ គណៈវិស្វករ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមករា ឆ្នាំ២០១៥*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា**ប្រចាំខែមករា ឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៥ ខែមិនាឆ្នាំ២០១៥ ដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមករាឆ្នាំ២០១៥សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ០,៤%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង០,៤%ធៀបនឹងខែដូច គ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់: | +៩% | សាច់ជ្រូក: | +៧,៤% |
| ភោជនីយដ្ឋាន: | +៤,៥% | ត្រីស្រស់: | +៥,៦% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ : | +៤% | បន្លែ: | +៥,៦% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមានជាតិស្រវឹង | +៣,៦% | ផ្លែឈើ: | +៤,១% |
| | | សាច់គោ: | +៣,៤% |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៣–២០១៥

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ P | មីនា P | មេសា P | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ០,៦% | ០,៧% | ០,៧% | | | | | | | | | |
| | មុន | -០,៤% | ០,២% | ០,៦% | ០,៥% | | | | | | | | | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៤,០% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | មុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |

**P**: តួលេខខែកុម្ភៈ មិនា និងមេសាឆ្នាំ២០១៥ ជាតួលេខព្យាករ (តាមវិធីសាស្រ្ត **DECOMPOSITION)**

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។ ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ គាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel ) សញ្ញាក្បៀសគាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| ប្រភេទ | មករា២០១៥ | ធ្នូ ២០១៤ | មករា២០១៤ | ប្រភេទ | មករា២០១៥ | ធ្នូ២០១៤ | មករា២០១៤ |
|---|---|---|---|---|---|---|---|
| ៛/ដុល្លារ | ៤០៦០៛/១$ | ៤០៧៥៛/១$ | ៣៩៩៥៛/១$ | បាត/ដុល្លារ | ៣២,៧៦បាត/១$ | ៣២,៨៨បាត/១$ | ៣៣,០១បាត/១$ |
| ៛/បាត | ១២៤៛/១បាត | ១២៤៛/១បាត | ១២១៛/១បាត | ដុង/ដុល្លារ | ២១៣២០ដុង/១$ | ២១៣៨០ដុង/១$ | ២១០៣៥ដុង/១$ |
| ៛/ដុង | ០,១៩០៛/១ដុង | ០,១៩១៛/១ដុង | ០,១៩០៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមករា ឆ្នាំ ២០១៥ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖



**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន៥៧៩,៧ពាន់លានរៀលក្នុងនោះចំណូលចរន្តចំនួន៤៧៥,៨ពាន់លានរៀល និងមិនមានចំណូលមូលធនទេ(តាមតួលេខរតនាគារជាតិ)។

- ➢បើធៀបនឹងខែមុនចំណូលថវិកាជាតិថយចុះ៦៤,៤% និងថយចុះ១៣,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ➢នៅក្នុងចំណូលចរន្ត:
  - ✓ចំណូលសារពើពន្ធមានចំនួន ៥៣៩,៤ពាន់លានរៀល ថយចុះ៥៥,២%ធៀបនឹងខែមុន និងថយចុះ១៦,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៣–២០១៥
(ពាន់លានរៀល)




  - ✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៤០,៣ពាន់លានរៀល ថយចុះ៨៦%ធៀបនឹងខែមុនប៉ុន្តែកើនឡើង ៥៣,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -៥,១% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១១,១%) | ➢ នេសាទ:+៤៩១,៧% | (-៧០,១%) |
| | | ➢រុក្ខាប្រមាញ់: | ( ) |
| ➢ ចំណូលពន្ធដារ: -១៨,២% (អគ្គនាយកដ្ឋានពន្ធដារ) | (+២៧,២%) | ➢សម្បទានរ៉ែ: -៧១% | (+៤,៧%) |
| | | ➢ អាកាសចរណ៍ស៊ីវិល:-៨៣,៣% | (-៤២,៣%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ:-៨២,៦% (តាមតួលេខ រតនាគារជាតិ) | (-៣០,៥%) | ➢ផលទុននៃសកម្មភាពទេសចរណ៍: | ( ) |
| | | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: -៩៥,៦% | (+២០,៣%) |
| ✧ កាស៊ីណូ :-៣១,១% | (+៥៣,៦%) | ➢អាករស្ថានទូត(លិខិតឆ្លងដែន និងទិដ្ឋាការ): -២៥,១% | (+៨២,៧%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -៩៩,៧% | (-៧០,២%) | ➢ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ: | |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : -៩៩,៦% | (-៩៨,៤%) | | ( ) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ៤៤៥,១ពាន់លានរៀល(*មធ្យមប្រចាំខែ ៣៦% នៃផែនការ*) ក្នុងនោះ: ចំណាយចរន្ត ចំនួន ៣៧៥,៨ពាន់លានរៀល (*មធ្យមប្រចាំខែ ៤៩% នៃផែនការ*) និងចំណាយមូលធនមានចំនួន ៦៩,២ពាន់លានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ៧០,១%ធៀបនឹងខែមុនប៉ុន្តែកើនឡើង១០៧,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៦៦,៨%ធៀបនឹងខែមុនប៉ុន្តែកើនឡើង៨៤,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន **១៣៤,៧**ពាន់លានរៀល។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៣–២០១៥
(ពាន់លានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមករាឆ្នាំ២០១៥មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ**M** ₂ មានចំនួន៤៣៤៩៥ពាន់លានរៀល កើនឡើង២,២% ធៀបនឹងខែមុន និងកើនឡើង៣០,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។**ការកើនឡើងM₂** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ៥,៧% ប្រាក់បញ្ញើមានការកំណត់ និងសន្សំ៩,៩% និងប្រាក់បញ្ញើជារូបិយបណ្ណ១,៦%។

➢ក្នុងខែនេះ: ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៧,៩% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨២,១% នៃរូបិយវត្ថុM₂។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមករាឆ្នាំ២០១៥




តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ M₂ ឆ្នាំ២០១៥

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៩% | | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៦% | | | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែមករា២០១៥: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន



➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៤៣៦៩លានដុល្លារ កើនឡើង១,៨%ធៀបនឹងខែមុន និងកើនឡើង២៤,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១២៨៣៨ ពាន់លានរៀលកើនឡើង ៦,៩%ធៀបនឹងខែមុន និងកើនឡើង២២,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *មករា២០១៥* | *ធ្នូ២០១៤* | *មករា២០១៤* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល)<br>ក្នុងនោះ ជារៀល | ៣៩៤០៨<br>មិនទាន់មានតួលេខ | ៣៨៨៣៩<br>៤៤៩ | ៣១៥៤៥<br>៤៤៥ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | | ៨២១៩ | ៥៥៨០ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | | ៦,០២% | ៥,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | | ១៦,២៦% | ១៥,៧% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | | ៤,២៣% | ៤,២៧% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | | ១១,៥១% | ១១,៤៩% |

### ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមករាឆ្នាំ២០១៥ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៥៥ពាន់តោន ថយចុះ៤១%ធៀបនឹងខែមុន និងថយចុះ៤២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៣៩០GWHមានការថយចុះ៥%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៣៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គសនីមានចំនួន ៨៦,៤ GWHមានការថយចុះ១២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៣៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៤៩៨,២ លានដុល្លារកើនឡើង២១%បើធៀបនឹងខែមុន និងមានការកើនឡើង២៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន–មករា២០១៥* | *ចំនួន–ធ្នូ២០១៤* | *ចំនួន–មករា២០១៤* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៥ | ១៦ | ០ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៣០៦ | ១២៨៦ | ១០៩៣ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | | — | ២២ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | — | |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១៥១ពាន់ម²ថយចុះ៧៣%ធៀបនឹងខែមុន និងថយចុះ៩០%ធៀបនឹងខែដូចគ្នាឆ្នាំមុន។បើគិតជាសាច់ប្រាក់ស្មើនឹង៤៦,២លានដុល្លារថយចុះ៧៦%ធៀបនឹងខែមុន និងថយចុះ៩២%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² —មករា២០១៥ | ពាន់ម² —ធ្នូ២០១៤ | ពាន់ម² —មករា២០១៤ |
|---|---|---|---|
| ▪ លំនៅឋាន | ៦២,៣ | ៣៦២,១ | ៧៧៨,៧ |
| ▪ ឧស្សាហកម្ម | ៤៧,៤ | ១១៦,៣ | ១៦,២ |
| ▪ទេសចរណ៍ | ២៧,២ | ៣៣,៥ | ១៥,៦ |
| ▪ពាណិជ្ជកម្ម | ៣,៤ | ៤១,៣ | ៦២៧,៩ |
| ▪ផ្សេងៗ | ០,៧ | ២,០ | ២០,៤ |
| អនុញ្ញាតសរុប | ១៥១,០ | ៥៥៦,០ | ១៤៧៦,១ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺ លំនៅដ្ឋាន៤១,៣% និង ឧស្សាហកម្ម៣១,៤%នៃផ្ទៃក្រឡាសរុប។

### ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—មករា២០១៥ | នាក់—ធ្នូ២០១៤ | នាក់—មករា២០១៤ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ ) | ៩៧៧ | ១៦២១ | NA |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៨៧០ | ១២១៣៦ | ២៥៩៣ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៣១៩ | ៩៣០៩ | ១៥៧៧ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៥៥១ | ២៨២៧ | ១០១៦ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មករា២០១៥ | ធ្នូ២០១៤ | មករា២០១៤ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៩៨៤,៦ | ៥៩,៧ | ១០៦,៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៧៣,៦ | ២៦,០ | ៣,៥ |
| វិស័យឧស្សាហកម្ម (ក្នុងរង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣១០,៣<br>៣១,៤ | ២៤,៧<br>(៦,៦) | ១០២,៨<br>(១៨) |
| វិស័យទេសចរណ៍ | ៣០០,៩ | ៩ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១៩៩,៨ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៨០ | ៨ | ២៤ |
| បង្កើតការងារ (ពាន់នាក់) | ១០៦,៧ | ៣៨,៨ | ២៨,៧ |

### ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —មករា២០១៥ | ចំនួន—ធ្នូ២០១៤ | ចំនួន—មករា២០១៤ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | ២៨៣ | ៣៩៥ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | ១០ | ៣ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | | |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៧០៣,៥ពាន់តោនកើនឡើង៦%ធៀបនឹងខែមុនប៉ុន្តែថយចុះ៨%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-២០% | (-១១%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+៩% | (-៧២%) |
| ▪ កំពង់ផែកំពង់សោម:+៣៨% | (+៣៨%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៣២% | (-២៩%) |

➢**ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៨,៧ | ៦% | ៨៨% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៤,៧ | ៣% | ៧១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥៧៥,៩ | ៩% | ៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | | | |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមករាមានចំនួន ៣៧០៥,៥ពាន់លានរៀល (ស្មើនឹង ៩២៦,២ លានដុល្លារ ស.រ.អា.)ថយចុះ១០,៣%ធៀបនឹងខែមុនប៉ុន្តែកើនឡើង១៧,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -២,៩% | +៣,២% | រថយន្តសរុប (ព.ល.រ) | -១១,២% | +២៣,៨% |
| ប្រេងម៉ាស៊ូត | +៨% | +២៩,១% | រថយន្តសរុប (គ្រឿង) | -២៦,២% | +៥,៩% |
| ឧស្ម័ន | +១,៧% | +៥៦,២% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +១,៤% | +៨,៣% |
| អគ្គិសនីនាំចូល | -៩,៨% | -២៥,១% | ម៉ូតូ (គ្រឿង) | -១,១% | +៥,៨% |
| ដែកសំណង់ | -១៧,៧% | -១១,៥% | អង្ករ | +១១៣,៨% | -៣៦,២% |
| ស៊ីម៉ង់ត៍ | +១៩,៤% | -១,៦% | ផ្លែឈើនិងបន្លែ | -១៤,៩% | -៥៥,៥% |
| គ្រឿងអេឡិចត្រូនិក | -២១,៦% | -៤៦,៥% | ជីនិងថ្នាំកសិកម្ម | -៥៧,៣% | -១៧,១% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +២,៥% | +១៣,៦% |

➡ **ការនាំចេញ** ខែមករាឆ្នាំ២០១៥ មានចំនួន**៣៤៥៣,៤**ពាន់លានរៀល ស្មើនឹង**៨៦៣,៣**លានដុល្លារ ស.រ.អា. (**៩៣,២%** នៃការនាំចូល)កើនឡើង២១,៣%ធៀបនឹងខែមុននិងកើនឡើង២៧,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +២៩០,៨% | -៦៥,៧% | ផលិតផលនេសាទ | | |
| វាយនភណ្ឌនិងស្បែកជើង | +១៩,៩% | +១៦,៧% | កៅស៊ូ | +១៤,៤% | +៤៦,៥% |
| អង្ករ | -៩,៣% | +៧៧% | | | |

➡ក្នុងខែមករានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ២៥២,១៣ពាន់លានរៀលស្មើនឹង៦៣លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមករាឆ្នាំ២០១៥នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | -៩៩,៧% | -៧០,២% | — |
| ២ | សំណង់អនុញ្ញាតឲ្យសាងសង់ (ពាន់ម$^២$) | -៧៣% | -៩០% | ការថយចុះយ៉ាងគំហុកនេះ អាចមកពីការខ្វះតួលេខពីបណ្តាខេត្តមួយចំនួន |

## ៧) សេចក្តីសន្និដ្ឋាន

អង្គប្រជុំបានផ្តោតជាសំខាន់លើផលវិបាកនៃចំណាកស្រុកនៃពលករខ្មែរទៅបរទេស។ ក.ស.វ សូមធ្វើការវិភាគវាយតម្លៃសង្ខេបអំពីបញ្ហានេះដូចតទៅ :

សេដ្ឋកិច្ចកម្ពុជាកំពុងមានកំណើនខ្ពស់ជាមួយនឹងសកម្មភាពវិនិយោគយ៉ាងខ្លាំងក្លា និងតម្រូវការជំលើកម្លាំងពលកម្ម ប៉ុន្តែទន្ទឹមនឹងនោះ ក៏មានចំណាកស្រុកនៃកម្លាំងពលកម្មពីជនបទមកទីក្រុង និងចេញទៅក្រៅប្រទេសយ៉ាងសន្ធឹកសន្ធាប់។ ផលិតកម្មក្នុងស្រុកខ្វះបុគ្គលិក-កម្មករ រីឯពួកគេក៏ពុំមានពត៌មានគ្រប់គ្រាន់អំពីទីផ្សារការងារក្នុងស្រុក។ ក្នុងរយៈពេល៥ឆ្នាំ (២០១០–២០១៤) តាមតួលេខផ្លូវការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្មករទទួលបានការងារទៅក្រៅប្រទេសមានចំនួនប្រហែល១១ម៉ឺននាក់ និងអ្នកទទួលការងារក្រៅផ្លូវការមានចំនួនលើសនេះច្រើនដង។ នេះជាវិបត្តទីផ្សារការងារដ៏សាំញ៉ាំនៃសេដ្ឋកិច្ចកម្ពុជា—ក្រុមហ៊ុនក្នុងស្រុកទាំងជាតិទាំងអន្តរជាតិប្រកួតគ្នាដណ្តើមពលករក្នុងវិស័យជាច្រើនដូចជា ឧស្សាហកម្ម សំណង់ សេវាកម្ម និងកសិកម្មជាដើម ប៉ុន្តែបែរជាមានលំហូរយ៉ាងខ្លាំងទៅក្រៅស្រុក។

ពលករកម្ពុជាធ្វើចំណាកស្រុកដើម្បីស្វែងរកឱកាសការងារ និងផ្ញើរកម្រៃ (Remittance)មកក្រុមគ្រួសារ។ ប៉ុន្តែគួរឲ្យសោកស្តាយ ចំណាកស្រុករបស់ពួកគេទៅក្រៅប្រទេស តែងមានការជួបប្រទះនូវភាពងាយរងគ្រោះជាច្រើន ដូចជាការជួញដូរមនុស្ស កម្រៃទទួលបានមានចំនួនតិចជាងការរំពឹងទុក ។ល។ ម្យ៉ាងវិញទៀតសេដ្ឋកិច្ចកម្ពុជាអាចនឹងមានកំណើនខ្ពស់ជាងនេះទៀត ប្រសិនបើមានការគ្រប់គ្រងឲ្យបានល្អអំពីចំណាកស្រុករបស់ពលករជាដោយឡែក និងទីផ្សារការងារទាំងមូលជារួម។

រាជរដ្ឋាភិបាលទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ជាពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរចាត់វិធានការសមស្រប និងប្រុងប្រយ័ត្ន ដើម្បីគ្រប់គ្រងទីផ្សារការងារឲ្យមានប្រសិទ្ធភាព។ គួរមានការប្រមូលពត៌មាន និងការសិក្សាអំពីមូលហេតុចំណាកស្រុក ដើម្បីជួយអ្នកធ្វើគោលនយោបាយ ក្នុងការបង្កើតយុទ្ធសាស្ត្រស្វែងយល់បរិយាកាសចំណាកស្រុក និងបង្វែរកម្លាំងពលកម្មមួយចំនួនឲ្យមកបម្រើការងារក្នុងស្រុកទៅតាមតម្រូវការ។ គួរកត់សម្គាល់ថា ក្នុងការប្រកួតប្រជែងដណ្តើមយកពលករ ក្រុមហ៊ុនបរទេសបានប្រើគ្រប់មធ្យោបាយដូចជា ការបណ្តុះបណ្តាល ការអូសទាញនិងផ្សព្វផ្សាយ និងការដាក់បណ្តាញតាមតំបន់សំខាន់ៗ។

អ្វីដែលគួរចាប់ផ្តើមនោះគឺ ការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ទីជនបទ អំពីសក្តានុពលទីផ្សារការងារក្នុងស្រុក សហការជាមួយភាគីឯកជនដើម្បីបង្កើតបរិយាកាសការងារល្អ រួមទាំងការស្នាក់នៅ ថ្លៃឈ្នួលផ្ទះ និងលទ្ធភាពបង់ថ្លៃទឹកភ្លើង។ លើសពីនេះទៀត គួរបង្កើនការផ្តល់មូលនិធិសម្រាប់ការទ្រទ្រង់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការគិតគូរលើកទឹកចិត្តដល់ការចាប់ផ្តើមធុរកិច្ចខ្នាតតូចរបស់គ្រួសារមួយចំនួនដែលវិលត្រលប់មកវិញ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | **០២/០២/១៥ ម៉ោង១៦:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសិក្ខាសាលាអន្តរជាតិ ផ្សព្វផ្សាយសៀវភៅដែលមានចំណងជើងថា "ស៊ីជីង ភីង" អភិបាលកិច្ចល្អរបស់ប្រទេសចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | **០៣/០២/១៥ ម៉ោង ១៩:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងសន្និសីទពិភពលោក ស្តីពីទេសចរណ៍ និងវប្បធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ Le Meridien Angkor។ |
| ៣ | **០៤/០២/១៥ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកជាផ្លូវការសន្និសីទពិភពលោក ស្តីពីទេសចរណ៍ និងវប្បធម៌ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសណ្ឋារគារ Le Meridien Angkor ខេត្តសៀមរាប។ |
| ៤ | **០៤/០២/១៥ ម៉ោង១៩:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីលៀងសាយភោជន៍ និងសម្តែងសិល្បៈជូនគណៈប្រតិភូជាតិនិងអន្តរជាតិ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅបរិវេណទីលានជល់ដំរី ខេត្តសៀមរាប។ |
| ៥ | **០៥/០២/១៥ ម៉ោង ១៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និសីទពិភពលោក ស្តីពីទេសចរណ៍ និងវប្បធម៌ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ Le Meridien Angkor។ |
| ៦ | **១០/០២/១៥ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ជូនដល់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហា សេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៧ | **១១/០២/១៥ ម៉ោង ០៩:០០នាទី** | ចូលរួមជួបពិភាក្សាការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ៨ | **១២/០២/១៥ ម៉ោង ០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | **១២/០២/១៥ ម៉ោង ១៥:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយភាគីចិន អំពីការងារសហប្រតិបត្តិការបច្ចេកទេសសម្រាប់អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១០ | **១៣/០២/១៥ ម៉ោង ១៦:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបញ្ចុះបឋមសិលា សម្រាប់សាងសង់អគារបណ្តុះបណ្តាល មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១១ | **១៦/០២/១៥ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៤ និងផែនការសកម្មភាពការងារឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១២ | **១៧/០២/១៥ ម៉ោង ០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់វិញ្ញាបនបត្រ និងសញ្ញាបត្រ ជូនសិក្ខាកាមវិជ្ជាជីវៈ និស្សិតថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃសាកលវិទ្យាល័យធនធានមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៣ | **១៩/០២/១៥ ម៉ោង ១៥:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម Jean MOREL នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២១-២៣/០២/១៥** | ចុះទស្សនកិច្ច ដើម្បីពិនិត្យគម្រោងសាងសង់អាកាសយានដ្ឋានអន្តរជាតិ នៅខេត្តកោះកុង របស់ក្រុមហ៊ុន Union Development Group ។ |
| ១៥ | **២៤/០២/១៥ ម៉ោង ០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរ"ទិវាជាតិទីក្រុងស្អាត" លើកទី៣ ក្រោមប្រធានបទ"ជោគជ័យទីក្រុងស្អាត ជោគជ័យទេសចរណ៍" និងពិធីប្រគល់ជ័យលាភីទីក្រុងស្អាតជូនក្រុង-ខណ្ឌបេក្ខភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ។ |
| ១៦ | **២៥/០២/១៥ ម៉ោង ១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងាររៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការដាក់ឲ្យអនុវត្តនូវវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៧ | **២៥/០២/១៥ ម៉ោង ១៧:១៥នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម Kelly Bird នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **២៦/០១/១៥ ម៉ោង ០៨:០០នាទី** | ចូលរួមអមដំណើរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ក្នុងពិធីបើកសន្និសីទអន្តរជាតិស្តីពីខួបលើកទី១០ នៃទំនួលខុសត្រូវក្នុងការ ការពារមនុស្សជាតិ វឌ្ឍនភាព បញ្ហាប្រឈម និងកាលានុវត្តភាពនៅអាស៊ីប៉ាស៊ីហ្វិក នៅសណ្ឋាគារ សូហ្វីតែលភ្នំពេញភូគីត្រា។ |
| ១៩ | **២៦/០២/១៥ ម៉ោង ១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីពិនិត្យលើការងារសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in